សង្ខេបសម្រាប់ គោលនយោបាយ

CDRI គឺជាវិទ្យាស្ថានកម្ពុជា ឯករាជ្យ ឈានមុខ
សម្រាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

ឆ្នាំ ២០១១ លេខ ១៣

# ការវាយតម្លៃពីកម្រិតពឹងផ្អែករបស់គ្រួសារទៅលើព្រៃឈើ៖ លទ្ធផលបានពី តំបន់សិក្សាបីនៅកម្ពុជា[1]

*លោក កុយ រ៉ា លោក លន់ ពេជ្រតារា និង លោក អ៊ុច ឈួង*[2]

## ខ្លឹមសារសំខាន់ៗ៖

- ព្រៃឈើ ជាប្រភពធនធានដ៏សំខាន់សម្រាប់ជួយទ្រទ្រង់ជីវភាពប្រជាជនកម្ពុជានៅជនបទ និងរក្សាលំនឹងអាកាសធាតុ។
- ការអភិវឌ្ឍសេដ្ឋកិច្ច និងកំណើនប្រជាជនឆាប់រហ័ស កំពុងដាក់សម្ពាធកាន់តែខ្លាំងទៅលើ ធនធានព្រៃឈើដែលនៅសេសសល់។
- ផលព្រៃឈើ និងអនុផលព្រៃឈើដែលប្រមូលយកសម្រាប់ផ្គត់ផ្គង់ទីផ្សារកន្លងមក គេបានធ្វើការវាយតម្លៃ និងកត់ត្រា។ ប៉ុន្តែការវាយតម្លៃលើផលប្រមូលមកពីបរិស្ថានព្រៃឈើ និងមិនមែនព្រៃឈើ សម្រាប់ការចិញ្ចឹមជីវិតក្នុងគ្រួសារ (គិតបញ្ចូលទាំងការប្រើប្រាស់ និងជួញដូរ) នៅកម្ពុជា ពុំមានការកត់ត្រាគ្រប់ជ្រុងជ្រោយទេ។
- ត្រូវមានវិធីសាស្ត្រដ៏សក្តិសិទ្ធិ សម្រាប់កំណត់ពីគុណតម្លៃនៃបរិស្ថានព្រៃឈើ និងមិនមែនព្រៃឈើ ចំពោះជីវភាពរស់នៅរបស់គ្រួសារនៅកម្ពុជា ដើម្បីធានាគុណភាពទិន្នន័យ និងព័ត៌មានច្បាស់លាស់ ផ្តល់ទៅជូនអ្នកធ្វើសេចក្តីសម្រេចចិត្ត ហើយញ៉ាំងឲ្យមាន ការរៀបចំគ្រប់គ្រងធនធានដ៏សំខាន់ទាំងនេះ ប្រកបដោយនិរន្តរភាព។

## បញ្ហាចោទ

បច្ចុប្បន្ន មានប្រជាជនក្រីក្ររាប់រយលាននាក់ កំពុងរស់នៅក្នុង ឬក្បែរតំបន់ព្រៃ និងមានភស្តុតាងបង្ហាញថា មួយចំនួនធំកំពុងប្រមូលយកផលព្រៃឈើយ៉ាងច្រើនៗ នៅតាមតំបន់ព្រៃស្ទើរគ្រប់ប្រភេទក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ (Scoones *et al.* 1992; Pérez & Arnold 1996; Neumann & Hirsh 2000; Cunningham 2001)។ គេបានបង្កើតក្របខ័ណ្ឌមួយចំនួនសម្រាប់វាយតម្លៃ និងស្វែងយល់ពីការពឹងផ្អែកលើព្រៃឈើ (Byron & Arnold 1999) និងអន្តរកម្មឥតឈប់រវាងព្រៃឈើ និងមនុស្ស (Wiersum 1997)។ ទោះជាយ៉ាងនេះក្តី ការស្រាវជ្រាវពីតួនាទី និងសក្តានុពលនៃព្រៃឈើក្នុងការការពារ និងកាត់បន្ថយភាពក្រីក្រមានតិចតួចនៅឡើយ ហើយអាចចាត់ទុកជាវិស័យមួយថ្មីសម្រាប់អង្កេត។ ការសិក្សាពីមុនៗ ត្រូវបានលើកមកពិនិត្យយ៉ាងល្អិតល្អន់ដើម្បីស្វែងយល់ពី ចំណងទាក់ទងរវាងភាពក្រីក្រ និងព្រៃឈើ ព្រមទាំងសក្តានុពលនៃព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ (Arnold & Bird 1999; Arnold 2001; Wunder 2001; Angelsen & Wnder 2003; Scherr et al. 2004; Sunderlin & Ba 2005)។ អត្ថបទរបស់ធនាគារពិភពលោកមួយ បានប្រើប្រាស់ការវិភាគលទ្ធផលរួមគ្នាលើ ៥៤ករណីសិក្សា ដើម្បីវាយតម្លៃពីភាពពឹងផ្អែកនៃប្រជាជននៅជនបទទៅលើចំណូលពីព្រៃឈើ និងផ្តល់អនុសាសន៍ស្តីពី វិធីសាស្ត្រស្រាវជ្រាវដ៏សមស្របនានា (Vedeld *et al.* 2004)។ អត្ថបទនេះបង្ហាញថា ជាទូទៅលទ្ធផលបានពីករណីសិក្សាទាំងនោះ មិនអាចប្រៀបធៀបគ្នាបានទេ ដោយសារការប្រើវិធីសាស្ត្រស្រាវជ្រាវខុសៗគ្នា។ ដូច្នេះ ចំណេះដឹងពីតួនាទីជាក់ស្តែង និងជាសក្តានុពលនៃព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ គឺនៅមានកម្រិតនៅឡើយ ហើយការយល់ឃើញពីតួនាទីនៃព្រៃឈើ ក្នុងការផ្តល់មធ្យោបាយឲ្យចាកផុតពីភាពក្រីក្រ គឺមានតាំងពីទុទិដ្ឋិនិយម (ឧទាហរណ៍ Wunder 2001) រហូតដល់សុទិដ្ឋិនិយម (ឧទាហរណ៍ Scherr *et al.* 2004)។ ការប្រៀបធៀបលទ្ធផលនៃការសិក្សាវាយតម្លៃពីព្រៃឈើ តាមរបៀបខុសៗគ្នាទាំងនេះ វាចោទបញ្ហាខ្លាំង អាចថាធ្វើមិនកើតផង (Wollenberg & Nawir 1998; Sheil & Wunder 2002; Vedeld *et al.* 2004)។ ដូច្នេះដើម្បីបង្កើនការយល់ដឹង ត្រូវមានការសិក្សាស៊ីជម្រៅថ្មីៗ

---

១ អត្ថបទសង្ខេបគោលនយោបាយនេះ ដកស្រង់ចេញពីឯកសារពិភាក្សា និពន្ធដោយលោក កុយ រ៉ា លោក លន់ ពេជ្រតារា លោក យ៉ែម ដារារដ្ឋ លោក Xi Jiao និង លោក Carsten Smith-Hall ស្តីពី *"ការបង្កើនចំណេះដឹងពីភាពពឹងផ្អែកលើព្រៃឈើនៅកម្រិតគ្រួសារនៅប្រទេសកម្ពុជា៖ តំបន់សិក្សា វិធីសាស្ត្រ និងលទ្ធផលស្រាវជ្រាវបឋម"* ដែលស្ថិតក្នុងចំណោម ឯកសារពិភាក្សាស្តីពី ព្រៃឈើ និង ទេសភាព ៦០/២០១១ របស់សាកលវិទ្យាល័យ Copenhangen នៅប្រទេសដាណឺម៉ាក។

២ កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថាន CDRI។

ទៀត ដោយប្រើវិធីសាស្ត្រដូចគ្នា និងរបៀបអនុវត្តល្អៗ ដែលអាចយកមកប្រៀបធៀបគ្នា និងធ្វើសំយោគនូវលទ្ធផលបានពីតំបន់ផ្សេងៗគ្នាទាំងនោះ។

## ករណីសិក្សា

អត្ថបទនេះ បង្ហាញពីលទ្ធផលសំខាន់ៗរកឃើញក្នុងអង្កេតគ្រួសារដែលធ្វើឡើងក្នុងឆ្នាំ២០០៨ នៅ ១៥ភូមិ ស្ថិតក្នុង ៣ឃុំ គឺ **១**) ឃុំសង្កែសាទប ស្ថិតក្នុងខេត្តកំពង់ស្ពឺ ក្នុងតំបន់ចន្លោះជួរភ្នំក្រវាញ និងវាលទំនាបបឹងទន្លេសាប។ ឃុំនេះ មានរដូវប្រាំងខ្លី មិនដល់ ៤ខែទេ ទទួលទឹកភ្លៀងប្រចាំឆ្នាំកម្រិតទាបក្នុងចន្លោះពី ៨០០ ទៅ ១៤០០មីលីម៉ែត្រ (FA 2003) មានដីគ្របដណ្តប់ដោយព្រៃរបោះ ដែលភាគច្រើនជាដើមចុល្លព្រីក្ស និងមានមួយភាគស្ថិតក្នុងតំបន់ការពារធម្មជាតិភ្នំឪរ៉ាល់។ **២**) ឃុំទំរីងជាតំបន់ទំនាបដាច់ស្រយាលមួយនៃខេត្តកំពង់ធំ។ រដូវប្រាំងនៅតំបន់នេះ មានរយៈពេលវែងជាង ៤ខែ ហើយកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំមានពី ១៤០០ ទៅ ២០០០មីលីម៉ែត្រ ឬជាមធ្យម ១៧០០មីលីម៉ែត្រ *(ibid.)*។ មកទល់ឆ្នាំ២០០០ តំបន់នេះ គ្របដណ្តប់ដោយព្រៃស្រោង និងព្រៃរបោះ (FA 1999) និងដីព្រៃសម្បទាន (ក្រុមហ៊ុន Colexim Enterpise, GAT International និង Mieng Ly Heng Investment)។ នៅឆ្នាំ២០០២ ការកាប់ឈើត្រូវបានហាមឃាត់ ហើយគេក៏ចាត់ទុកតំបន់ព្រៃទាំងនោះថា បានបើកសម្រាប់ការប្រើប្រាស់រួម ដែលនាំឲ្យមានការកែប្រែផ្ទៃដីជាច្រើន។ **៣**) ឃុំតាកែន ស្ថិតក្នុងតំបន់ដាច់ស្រយាលមួយនៃខេត្តកំពត ក្នុងតំបន់ភ្នំក្រវាញជាប់ឆ្នេរសមុទ្រ។ ទឹកភ្លៀងប្រចាំឆ្នាំមានកម្រិតខ្ពស់ពី ២៦០០ ដល់ ៣២០០មីលីម៉ែត្រ (FA 2003)។ ឃុំនេះគ្របដណ្តប់ដោយព្រៃរបោះ ភាគច្រើនជាដើមចុល្លព្រីក្ស និងមានមួយភាគស្ថិតក្នុងឧទ្យានជាតិបូកគោ។ ព្រៃឈើនៅក្រៅតំបន់ឧទ្យានត្រូវបានបើកឲ្យប្រើប្រាស់រួម និងស្ថិតក្រោមសម្ពាធខ្លាំងនៃការកែប្រែការប្រើប្រាស់ដី។

ការសិក្សាបានជ្រើសរើសយក ៦០០គ្រួសារដោយចៃដន្យ ពោលគឺ ២០០គ្រួសារមកពីឃុំនីមួយៗ ឬ ៤០គ្រួសារមកពីភូមិនីមួយៗ (សរុប ១៥ភូមិ) ដែលស្មើនឹង ១០%-៣០% នៃចំនួនគ្រួសារសរុបក្នុងភូមិមួយៗ។ មុនចាប់ផ្តើមចុះទៅសិក្សាដល់កន្លែង ក្រុមស្រាវជ្រាវបានកសាងបញ្ជីឈ្មោះគ្រួសារទាំងអស់នៅក្នុង ១៥ភូមិដែលបានជ្រើសរើសនោះ ដោយប្រើប្រាស់សៀវភៅកំណត់ត្រាផ្លូវការធ្វើឡើងដោយមេភូមិ។ គ្រួសារទីមួយត្រូវបានជ្រើសរើសដោយចៃដន្យចេញពីបញ្ជី ហើយគ្រួសារបន្តបន្ទាប់ទៀត ត្រូវបានជ្រើសរើសរាល់ X/៤០ (X ជាចំនួនគ្រួសារសរុបនៅក្នុងភូមិនោះ)។ គ្រួសារត្រូវបានកំណត់ថា ជាមនុស្សមួយក្រុមដែលរស់នៅជាមួយគ្នា និងទទួលទានអាហារពីផ្ទះបាយរួមគ្នា លើកលែងតែតម្រូវការបំពេញការងារ មិនអាចឲ្យពួកគេធ្វើដូច្នេះបាន (NIS 2007)។

សម្ភាសន៍ បានអនុវត្តរៀងរាល់ ៣ខែម្តង ក្នុងឆ្នាំ២០០៨៖ សម្ភាសន៍នៅត្រីមាសទី១ ធ្វើឡើងនៅដើមខែមករា ហើយសម្ភាសន៍ត្រីមាសទី២ ទី៣ និងទី៤ បានបញ្ចប់នៅចុងខែមីនា កក្កដា និងតុលា រៀងគ្នា។ បញ្ជីសំណួរ ត្រូវបានរៀបចំ និងបកប្រែជាភាសាខ្មែរ ដោយផ្តោតលើ ការប្រមូលផល (កែច្នៃរួច និងមិនទាន់កែច្នៃ) ពីបរិស្ថានព្រៃឈើ បរិស្ថានមិនមែនព្រៃឈើ ដំណាំកសិកម្ម និងការលក់កម្លាំងពលកម្ម (ក្រៅកសិដ្ឋាន)។ ទិន្នន័យទាំងនោះ អាចប្រៀបធៀបគ្នាបានជាមួយនឹងទិន្នន័យដែលបានប្រមូលសម្រាប់ការសិក្សាឯទៀតៗនៅក្នុងប្រទេសក្រោមបណ្តាញខាងបរិស្ថាន និងភាពក្រីក្រ (PEN)។

គេបានប្រើប្រាស់វិធីសាស្ត្រ ៣ សម្រាប់កំណត់តម្លៃផលិតផលនីមួយៗ៖ ១) ការកំណត់តម្លៃនៅទីផ្សារមូលដ្ឋាន ដោយផ្អែកលើថ្លៃនៅកសិដ្ឋាន ២) ការកំណត់តម្លៃជំនួស (substitute valuation) ដោយផ្អែកលើថ្លៃនៅទីផ្សារមូលដ្ឋាននៃផលិតផលប្រហាក់ប្រហែលគ្នាបំផុតអាចជំនួសគ្នាបាន និង ៣) ការកំណត់តម្លៃតាមការចំណាយពេលវេលា (time spent valuation) ដោយផ្អែកលើចំនួនពេលធ្វើពលកម្ម គុណនឹងអត្រាថ្លៃឈ្នួលប្រចាំថ្ងៃនៅមូលដ្ឋាន (ប្រែប្រួលតាមរដូវកាល និងភេទ)។

## លទ្ធផលស្រាវជ្រាវសំខាន់ៗ

ការសិក្សាបានកត់ត្រានូវផលិតផលនិងសេវាកម្ម២១៦ប្រភេទ ក្នុងនោះមាន ៨២ ជាផលដំណាំ ៦១ ជាផលិតផលព្រៃឈើ ៥៩ ជាផលខាងបរិស្ថាន និង ១៤ ជាសេវាកម្មនិងផលបានពីសត្វចិញ្ចឹម។ គ្រួសារនានានៅគ្រប់តំបន់សិក្សា តែងប្រមូលផលព្រៃឈើ និងផលខាងបរិស្ថានមិនមែនព្រៃឈើ។ ផលិតផលព្រៃឈើដែលប្រមូលយកជាទូទៅ មាន ឧស (៨៥%) ឫស្សី (៤២%) និងផ្លែឈើព្រៃ (៣២%)។

ចំណូលគ្រួសារប្រចាំឆ្នាំជាមធ្យម នៅក្នុងតំបន់សិក្សាទាំង៣ មានចាប់ពី ២,៣៣លានរៀល (៥៧៣ដុល្លារ) ដល់ ២,៧៨លានរៀល (៦៨៤ដុល្លារ)។ ការធ្វើស្រែចំការ ជាប្រភពចម្បងនៃចំណូលប្រចាំឆ្នាំរបស់គ្រួសារនានានៅតំបន់ទាំង៣នោះ ដោយមានចំណែកពី ៤៤% (ក្នុងខេត្តកំពង់ស្ពឺ) ដល់ ៦០% (ក្នុងខេត្តកំពត)។ ព្រៃឈើក៏ដើរតួនាទីសំខាន់ដែរ ក្នុងការបង្កើតចំណូល ដោយរួមចំណែក ៣៤% នៃចំណូលប្រចាំឆ្នាំសរុបក្នុងខេត្តកំពង់ស្ពឺ ២១% ក្នុងខេត្តកំពង់ធំ និង ២៣% ក្នុងខេត្តកំពត។ ប្រភពចំណូលបានពីខាងបរិស្ថាននៅក្នុងតំបន់ទាំង៣ មានទំហំតិចតួចប្រមាណពី ៧-៨% នៃចំណូលសរុបក្នុងខេត្តកំពង់ស្ពឺ និងកំពត និង ២% ក្នុងខេត្តកំពង់ធំ។ ភាគរយចំណូលបានពីការងារក្រៅកសិដ្ឋាន ប្រែប្រួលទៅតាមតំបន់ ដោយមានកម្រិតខ្ពស់បំផុតក្នុងខេត្តកំពង់ធំ (២៣%) ដែលខ្ពស់ជាងចំណូលបានពីព្រៃឈើបន្តិច (២១%) និងទាបបំផុតក្នុងខេត្តកំពត (៩%)។ រូបភាព១ បង្ហាញពីធាតុផ្សំនៃប្រភពចំណូលផ្សេងៗ នៅតាមតំបន់សិក្សានីមួយៗ។

បរិមាណចំណូល ប្រែប្រួលចុះឡើងតាមរដូវកាល ប៉ុន្តែផលិតផលកសិកម្មនៅតែជាប្រភពចំណូលចម្បងក្នុងតំបន់សិក្សាទាំង៣ រីឯធនធានព្រៃឈើ ជាប្រភពចំណូលទី២ សម្រាប់ស្ទើរគ្រប់តំបន់សិក្សា (រូបភាព២)។

រូបភាព១៖ ចំណែកក្នុងចំណូលប្រចាំឆ្នាំសរុបរបស់គ្រួសារ គិតតាមប្រភពចំណូល ឆ្នាំ២០០៨




នៅតំបន់សិក្សាក្នុងខេត្តកំពត ចំណែកនៃចំណូលបានពីព្រៃឈើមាននិន្នាការកើនឡើងពី ១៧% នៅក្នុងក្រុមចតុភាគ (quartile) ទាបបំផុត ដល់ ២៦% នៅក្រុមចតុភាគខ្ពស់បំផុត ហើយបើគិតជាទឹកប្រាក់វាកើនឡើងមួយជាពីរ ពីក្រុមចតុភាគមួយទៅក្រុមចតុភាគបន្ទាប់ ដូច្នេះ ក្រុមចតុភាគខ្ពស់បំផុតរកបាន ៨ដងច្រើនជាងក្រុមចតុភាគទាបបំផុត។ ផលពីព្រៃឈើមិនទាន់កែច្នៃមានចំណែកធំបំផុត នៅក្នុងចំណូលបានពីព្រៃឈើសរុបគឺ ពី ៥១% ទៅ ៧៣%។ ចំណូលបានពីផលព្រៃឈើកែច្នៃរួចមានកាន់តែច្រើនឡើង នៅពេលចំណូលសរុបរបស់គ្រួសារកើនឡើង។

នៅតំបន់សិក្សាក្នុងខេត្តកំពង់ស្ពឺ ព្រៃឈើដើរតួនាទីយ៉ាងសំខាន់ និងរួមចំណែកពី ២៩% ទៅ ៣៦% នៃចំណូលសរុបរបស់គ្រួសារ។ បើគិតជាតម្លៃសរុប ចំណូលពីព្រៃឈើក្នុងខេត្តកំពង់ស្ពឺ មានកម្រិតខ្ពស់ជាងតំបន់សិក្សាពីរផ្សេងទៀត នៅគ្រប់ក្រុមចំណូលចតុភាគ។ ចំណូលពីផលព្រៃឈើកែច្នៃរួចរួមចំណែកធំបំផុត (ច្រើនជាង ៦០%) ក្នុងចំណូលបានពីព្រៃឈើ លើកលែងនៅក្រុមចតុភាគទាបបំផុត ដែលចំណូលនេះមានចំណែកស្មើនឹងចំណូលពីផលព្រៃឈើមិនទាន់កែច្នៃ។

នៅតំបន់សិក្សាក្នុងខេត្តកំពង់ធំ ព្រៃឈើក៏ជាប្រភពចំណូលសំខាន់ដែរ ដោយរួមចំណែកពី ២០% ទៅ ២៣% នៃចំណូលសរុបរបស់គ្រួសារ បើទោះជាវាមានតម្លៃសរុបជាទឹកប្រាក់ទាបជាងគេក្នុងចំណោមតំបន់សិក្សាទាំង៣ និងសម្រាប់គ្រប់ក្រុមចតុភាគចំណូលក្តី។ ប្រភពចំណូលចម្បងពីព្រៃឈើគឺ ផលព្រៃឈើមិនទាន់កែច្នៃ។ ចំណូលពីថ្លៃឈ្នួលពលកម្មទាក់ទងនឹងព្រៃឈើរួមចំណែកពី ៨% ទៅ ១០% នៃចំណូលសរុបរបស់ ៣ក្រុមចំណូលចតុភាគទាបៗ ហើយតួលេខនេះវាខ្ពស់ជាខ្លាំង បើធៀបនឹងតំបន់សិក្សាពីរផ្សេងទៀត។ ចំណូលពីព្រៃឈើកែច្នៃរួច កាន់តែសំខាន់ខ្លាំងឡើងនៅក្នុងក្រុមចតុភាគចំណូលខ្ពស់បំផុត។

តាមការសិក្សា តំបន់សិក្សាទាំង៣ ធ្លាប់ជួបវិបត្តិមួយចំនួន ក៏ដូចជា បញ្ហាអាកាសធាតុមិនទៀងទាត់ដែលបណ្តាលឲ្យមានការបាត់បង់ទ្រព្យសម្បត្តិ និងផលកសិកម្ម។ អ្នកភូមិបានប្រើប្រាស់យុទ្ធសាស្ត្រជាច្រើន ដើម្បីដោះស្រាយបញ្ហាទាំងនោះ ហើយដំណោះស្រាយជាទូទៅមួយចំនួន មានបង្ហាញក្នុងតារាង១ ដែលរួមមាន ការចំណាយប្រាក់សន្សំ (២៣%) ការប្រមូលផលព្រៃឈើច្រើនជាងមុន (១៩%) ការធ្វើពលកម្មបន្ទាប់បន្សំបន្ថែម (១៣%) និងការលក់ទ្រព្យសម្បត្តិ (១២%)។ ចំណុចនេះបង្ហាញច្បាស់ថា ក្រៅពីផ្តល់នូវប្រភពសំខាន់សម្រាប់ការចិញ្ចឹមជីវិត និងចំណូលជាសាច់ប្រាក់ ព្រៃឈើ ក៏ជាធនធានមួយយ៉ាងសំខាន់សម្រាប់គ្រួសារនៅកម្ពុជាប្រើប្រាស់ទប់ទល់នឹងវិបត្តិផ្សេងៗផងដែរ។

## ផលប៉ះពាល់ផ្នែកគោលនយោបាយ

- ការវាយតម្លៃដោយប្រើសម្ភាសន៍ប្រចាំត្រីមាស អាចផ្តល់ព័ត៌មាន និងទិន្នន័យកាន់តែត្រឹមត្រូវឡើងសម្រាប់ផ្តល់ជូនអ្នកធ្វើគោលនយោបាយ។
- ធនធានព្រៃឈើ និងផលិតផលផ្នែកបរិស្ថានផ្សេងៗទៀត ដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់ និងកាត់បន្ថយភាពក្រីក្រ។ ដូច្នេះ ផលបានពីព្រៃឈើ និងបរិស្ថានមិនមែនព្រៃ គួរតែដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ ដើម្បីឲ្យគ្រួសារ និងសហគមន៍នៅជនបទ ទទួលបានអត្ថប្រយោជន៍ផងដែរ។

## ឯកសារយោង

Angelsen A. & S.Wunder (2003), "Exploring the forest-poverty link: key concepts, issues and research implications", CIFOR Occasional Paper No. 40

Arnold, J.E.M. (2001), "Forestry, poverty, aid", CIFOR Occasional Paper No. 33

Arnold, J.E.M. & P. Bird (1999),"Forests and the poverty-environment nexus", paper presented at the

រូបភាព២៖ ចំណូលប្រចាំឆ្នាំសរុបរបស់គ្រួសារ គិតតាមប្រភព និងត្រីមាស ឆ្នាំ២០០៨



☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

តារាង១៖ ការបូកសរុបពីប្រេហ្វកង់នៃការដោះស្រាយទប់ទល់នឹងវិបត្តិ

| តើអ្នកទប់ទល់យ៉ាងដូចម្តេច នៅពេលជួបនឹងការបាត់បង់ប្រាក់ចំណូល ឬទំនិញឡើងថ្លៃ? | ប្រេហ្វកង់ | ភាគរយ |
|---|---|---|
| ប្រមូលផលព្រៃឈើកាន់តែច្រើន | 96 | 18.9 |
| ប្រមូលអនុផលព្រៃឈើកាន់តែច្រើន | 5 | 1.0 |
| ប្រមូលផលកសិកម្មកាន់តែច្រើន | 28 | 5.5 |
| ចំណាយប្រាក់សន្សំ | 115 | 22.6 |
| លក់ទ្រព្យសម្បត្តិ (ដីធ្លី សត្វចិញ្ចឹម) | 59 | 11.6 |
| ធ្វើពលកម្មបន្ទាប់បន្សំបន្ថែម | 64 | 12.6 |
| ទទួលជំនួយពីមិត្តភក្តិ និងសាច់ញាតិ | 29 | 5.7 |
| ទទួលជំនួយពីអង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ | 7 | 1.4 |
| ខ្ចីបុលពី អ្នកចងការប្រាក់ សមាគមផ្តល់ឥណទាន | 44 | 8.6 |
| កាត់បន្ថយចំណាយគ្រួសារ | 1 | 0.2 |
| គ្មានធ្វើអ្វីជាពិសេសទេ | 44 | 8.6 |
| ផ្សេងៗ | 17 | 3.3 |
| សរុប | **509** | **100.0** |

UNDP/EC expert workshop on "Poverty and the Environment ', Brussels, Belgium, 20-21 January
Byron, N. & M. Arnold (1999), "What futures for the people of the tropical forests?" *World Development*, 27 (5), pp. 789-805
Cunningham, A.B. (2001), *Applied Ethno-botany*, (London: Earthscan Publications)
Forest Administration (2003), "Gene ecological zonation of Cambodia" (Phnom Penh: FA, Danish International Development Agency (Danida) & German Development Service)
Forest Administration (1999), "Forest Cover Assessment, Cambodia" (Phnom Penh: FA)
National Institute of Statistics (2007), *General Population Census of Cambodia, 2008: Enumerator's Manual* (Phnom Penh: Ministry of Planning)
Neumann, R.P. & E. Hirsch (2000), Commercialisation of Non-timber Forest Products: Review and Analysis of Research (Bogor: CIFOR)
Pérez, M.R. & J.E.M. Arnold (eds.) (1996), *Current Issues in Non-timber Forest Products Research* (Bogor: CIFOR)
Scherr, S.J., A. White & D. Kaimowitz (2004), *A New Agenda for Forest Conservation and Poverty Reduction: Making Markets Work for Low Income Producers* (Washington, DC: CIFOR & IUCN)
Scoones, I., M. Melnyk & J.N. Pretty (1992), *The Hidden Harvest: Wild Foods and Agricultural Systems* (London: IIED)
Sheil, D. & S. Wunder (2002), "The value of tropical forests to local communities: complications, caveats, and cautions", *Conservation Ecology*, 6 (2), pp. 9
Sunderlin, W.D. & H. T. Ba (2005), Poverty Alleviation and Forests in Vietnam (Bogor: CIFOR)
Vedeld, P., A. Angelsen, E. Sjaastad & G.K. Berg (2004), "Counting on the environment – forest incomes and the rural poor", Environmental Economics Series, Paper No. 98 (Washington, DC: World Bank Environment Department)
Wiersum, K.F. (1997), "Indigenous exploitation and management of tropical forest resources: an evolutionary continuum in forest-people interactions", *Agriculture, Ecosystems and Environment*, 63, pp. 1-16
Wollenberg, E. & A.S. Nawir (1998), "Estimating the Incomes of People who Depend on Forests", in E. Wollenberg & A. Ingles (eds.) *Incomes from the Forests* (Bogor, Indonesia: CIFOR) pp.157-187
Wunder, S. (2001), "Poverty alleviation and tropical forests – what scope for synergies?" *World Development*, 29 (11), pp. 1817-1833